# សក្ខីកម្មរបស់អ្នកយាមមន្ទីរស-២១ និងអ្នកជីករណ្តៅកប់សពនៅ ជើងឯក

*ញាណ សុជាតិ*

ឈុន ផល អាយុ ៤៧ឆ្នាំ មានទឹកមុខធម្មតា ស្ងួតត្រង់ និងមានអារម្មណ៍ស្រួល ខណៈពេលដែលគាត់បានផ្តល់សក្ខីកម្មជាមួយនឹងស្នាមញញឹមក្នុងតុលាការកាត់ទោស កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ បន្ទាប់ពីបានផ្តល់នូវសេចក្តីរាយការណ៍ជាលើកដំបូងដល់ចៅក្រមស៊ើបអង្កេតកាលពីដើម ឆ្នាំ២០០៨ ក្រោយមក ឈុន ផល បានបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាលពីថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៩ ដើម្បីផ្តល់សក្ខីកម្មទាក់ទិននឹងបទពិសោធន៍ជាអ្នកយាមមន្ទីរស-២១ និងរយៈពេលដ៏ខ្លីដែលគាត់បានចំណាយពេលធ្វើការនៅជើងឯក ជាកន្លែងសម្លាប់ដ៏ល្បីល្បាញដែលជាធម្មតាត្រូវបានគេស្គាល់ថា ជា«វាលពិឃាត» ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីបានចំណាយពេលរបស់ខ្លួនធ្វើការជាអ្នកយាមមន្ទីរស-២១ ។ យ៉ាងណាមិញ នៅឆ្នាំ១៩៧៨ មុនកងទ័ពវៀតណាមចូលដល់ក្រុងភ្នំពេញ ឈុន ផល ត្រូវបានបញ្ជូនទៅគុកព្រៃស និងវាលពិឃាតបឹងជើងឯក ជាកន្លែងដែលគាត់ធ្វើការងារដូចជាដាំបន្លែ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ។ នៅវាលពិឃាតបឹងជើងឯក សាក្សីត្រូវបានចាត់តាំងឲ្យកប់សាកសពអ្នកទោស ។

ក្នុងឆ្នាំ១៩៧៥ ឌុច បានស្នើថាក្រុមយុវជនដែលមានអាយុក្រោម ១៦ឆ្នាំ នៅខេត្តកំពង់ឆ្នាំង ត្រូវជ្រើសរើសឲ្យមកធ្វើការជាអ្នកយាមមន្ទីរស-២១ ។ ឌុច ចង់បានយុវជនមកពីគ្រួសារក្រីក្រដែលមិនធ្លាប់ជាប់ពាក់ព័ន្ធនឹងវគ្គបំពាក់បំប៉ននយោបាយពីមុនមក ។ យ៉ាងណាមិញ ឈុន ផល មិនបានដឹងថាគាត់ត្រូវបានគេជ្រើសរើសឲ្យធ្វើជាអ្នកយាមមន្ទីរស-២១តាមសំណូមពររបស់ ឌុច ឡើយ ។ ជាមួយគ្នានេះដែរ សាក្សីក៏មិនដែលបានជួប ឌុច ទោះបីជាក្នុងពេលដែលគាត់ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកយាមមន្ទីរស-២១ ។ សាមសិបឆ្នាំក្រោយពីបានលាឈប់ពីតំណែងជាអ្នកយាមមក នៅថ្ងៃនេះ សាក្សីទទួលបាននូវឱកាសដើម្បីផ្តល់សក្ខីកម្មនៅចំពោះមុខ ឌុច អតីតប្រធានរបស់ខ្លួន ។

## ចូលបដិវត្តន៍

នៅខេត្តកំពង់ឆ្នាំង មុននឹងខ្មែរក្រហមបានឡើងកាន់កាប់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ ប្រធានភូមិ បានចាត់តាំង ឈុន ផល ជាក្មេងប្រុសមានអាយុ ១៥ឆ្នាំ ឲ្យចូលបដិវត្តន៍ ។ ខ្មែរក្រហមបានបញ្ជូន ឈុន ផល ទៅឃុំសាលាលេខប្រាំ ប្រហែលជាមួយសប្តាហ៍ក្រោយមកក៏បញ្ជូនគាត់ទៅភ្នំពេញ ។ ក្រោយពីបានចំណាយពេលមួយខែនៅភ្នំពេញ ជាកន្លែងដែលគាត់បាននិយាយថា គាត់

បានធ្វើកិច្ចការតិចតួចណាស់នៅទីនេះ បន្ទាប់មក គាត់ត្រូវបានបញ្ជូនទៅហាត់វគ្គចម្បាំង និងការហ្វឹកហ្វឺនទ័ពទាហាននៅតាខ្មៅ ។

ដូចទាហានបដិវត្តន៍ដទៃទៀត ខ្មែរក្រហមបញ្ជូន ឈុន ផល ឲ្យធ្វើស្រែនៅ ព្រៃស ។ ឈុន ផល មិនបានចាំថាគាត់បានធ្វើការនៅ ព្រៃស អស់រយៈពេលប៉ុន្មាននោះទេ ប៉ុន្តែ ឈុន ផល បាននិយាយថា បន្ទាប់ពីធ្វើការនៅគ ព្រៃស គាត់ក៏មកធ្វើការជាអ្នកយាមនៅគុក ទួលស្លែង ។ ខណៈពេលដែលត្រូវបានសួរដោយចៅក្រមថាតើ គុក ទួលស្លែង មានឈ្មោះផ្សេងពីនេះនៅក្នុងពេលនោះដែរឬទេ ឈុន ផល បាននិយាយថា ពាក្យ ទួលស្លែង និងមន្ទីរស-២១គឺមានន័យដូចគ្នា ។

## ស្ថានភាពនៅមន្ទីរស-២១

តាមការចង់ចាំរបស់គាត់ ឈុន ផល បានរៀបរាប់ថា នៅមន្ទីរស-២១ មានអគារធំៗចំនួនបួន ហើយ ឈុន ផល ត្រូវបានចាត់តាំងឲ្យយាមអគារដែលមានបន្ទប់ច្រើនមួយក្នុងចំណោមអគារបី ។ នៅមន្ទីរស-២១ ឈុន ផល ជាមួយនឹងអ្នកយាមដប់មួយនាក់ទៀតបានដើរល្បាតជុំវិញមន្ទីរស-២១ និងត្រួតពិនិត្យអ្នកទោស ។ ក្នុងភារកិច្ចជាអ្នកយាម បុគ្គលិកមន្ទីរស-២១ បានបង្រៀន ឈុន ផល ឲ្យប្រុងប្រយ័ត្នជាមួយនឹងអ្នកទោសដែលមានបំណងលួចរត់ ឬសម្លាប់ខ្លួន ។ ឈុន ផល បានផ្តល់សក្ខីកម្មថា "នៅពេលយាមក្នុងបរិវេណគុក ខ្ញុំមានអាវុធជាប់ខ្លួន ប៉ុន្តែ ប្រសិនបើយាមនៅខាងក្រៅបរិវេណគុកវិញ ខ្ញុំមិនមានអាវុធឡើយ ។ ក្នុងករណីដែលអ្នកទោសគេខ្លួនបាត់ អ្នកយាមនឹងត្រូវចាប់ដាក់គុក ។

ឈុន ផល បានបន្តបន្ថែមទៀតថា អ្នកទោសត្រូវបានឃុំនៅក្នុងបន្ទប់ដាច់ដោយឡែកម្នាក់ៗ ឬក្នុងបន្ទប់រួម ។ ក្នុងបន្ទប់ឃុំអ្នកទោសដាច់ដោយឡែកម្នាក់ មានបង្អួចដើម្បីឲ្យអ្នកយាមអាចមើលឃើញអ្នកទោសតាំងពីផ្លូវដើរតាមបន្ទប់បាន ហើយអ្នកយាមត្រូវតែពិនិត្យមើលខ្នោះជើងអ្នកទោសជាប្រចាំ ។ ចំណែកនៅក្នុងបន្ទប់ឃុំអ្នកទោសរួមវិញ អ្នកទោសទាំងអស់ត្រូវបានដាក់ឃុំ និងដាក់ខ្នោះជើងរួមគ្នា ។ អ្នកយាមត្រូវពិនិត្យមើលគន្លឹះសោរខ្នោះថាត្រូវបានចាក់យ៉ាងត្រឹមត្រូវហើយ ។ អ្នកយាមទាំងអស់ត្រូវបំពេញភារកិច្ចរបស់ខ្លួនរយៈពេល ២៤ម៉ោងក្នុងមួយថ្ងៃ និងប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ។ នៅពេលយប់ មន្ទីរស-២១មានភ្លើងអគ្គិសនីគ្រប់គ្រាន់ដើម្បីឲ្យអ្នកយាមអាចមើលឃើញ ។

### អ្នកទោស

យោងតាមសម្តីរបស់ ឈុន ផល អ្នកទោសទាំងអស់មានរូបរាងស្គមស្គាំង និងត្រូវបានផ្តល់អាហារសម្រាប់ហូបតិចតួចណាស់ ។ អ្នកទោសប្រុស ត្រូវយាមគានតឹងជាអ្នកទោសស្រី ។ អ្នកទោសប្រុសទោសប្រុសត្រូវបានដាក់ខ្នោះជើង និងឃុំក្នុងបន្ទប់ដាច់ដោយឡែកម្នាក់ ឬក្នុងបន្ទប់រួម ចំណែក

ឯអ្នកទោសស្រីវិញ មិនត្រូវបានដាក់ខ្នោះដៃ ឬជើងទេ ប៉ុន្តែត្រូវដាក់ឃុំក្នុងបន្ទប់ដ៏មានសុវត្ថិភាព។ អ្នកទោសប្រុសត្រូវតែសុំការអនុញ្ញាតពីអ្នកយាមមុននឹងគេអាចក្រោកឈរ។ អ្នកទោសទាំង អស់ពាក់សម្លៀកបំពាក់ចាស់ៗ និងរហែក អ្នកខ្លះពាក់ខោខ្លី ខោជើងវែង ហើយអ្នកខ្លះទៀតមិនមានពាក់អាវ។ ឈុន ផល បានផ្តល់សក្ខីកម្មថា អ្នកទោសខ្លះមានកូនមកជាមួយ ប៉ុន្តែក្មេងទាំងនោះបានបាត់ខ្លួនពីរ ឬបីថ្ងៃក្រោយពីម្តាយគេត្រូវជាប់ឃុំឃាំង។ ចំណែកឯអ្នកទោសជនជាតិបរទេសត្រូវឃុំក្នុងបន្ទប់ដាច់ដោយឡែកពីអ្នកទោសខ្មែរ។

## ការកប់សាកសពអ្នកទោស

ខណៈពេលដែលត្រូវបានសួរជាលើកដំបូងដោយលោកប្រធានចៅក្រម និល ណុន ថាតើ ឈុន ផល បានឃើញអ្នកទោសត្រូវគេបាននាំចេញ ហើយដឹងថាតើកន្លែងណាដែលអ្នកទោសទាំងនោះត្រូវនាំទៅដែរឬទេនោះ ឈុន ផល បាននិយាយថាគាត់មិនបានដឹងទេ ៖ "អ្នកទោសត្រូវបាននាំចូល និងនាំចេញ អ្នកទោសខ្លះបាននាំត្រឡប់មកវិញ ខ្លះទៀតក៏បាត់ខ្លួនសូន្យ។ ខ្ញុំមិនបានដឹងថាអ្នកទោសត្រូវនាំទៅកន្លែងណាទេ។" យ៉ាងណាមិញ មុននឹងកងទ័ពវៀតណាមចូលមកដល់ ឈុន ផល បានទៅវាលពិឃាត ជើងឯក។ ជាមួយគ្នានេះ ឈុន ផល បាននិយាយថាបុគ្គលិករបស់មន្ទីរស-២១ម្នាក់បានបញ្ជូនគាត់មកជើងឯក ដើម្បីកប់សាកសព។

ចម្លើយរបស់ ឈុន ផល បានធ្វើឲ្យលោកប្រធានចៅក្រមចាប់អារម្មណ៍ ហើយក៏បន្តសួរសំណួរបន្ថែមទៀតថាតើអ្នកយាមធ្វើយ៉ាងដូចម្តេចចំពោះសាកសពអ្នកទោស។ ឈុន ផល បានផ្តល់សក្ខីកម្មថា នៅថ្ងៃមួយប្រហែលជាម៉ោងប្រាំមួយល្ងាច គាត់ត្រូវបានគេប្រាប់ឲ្យទៅ ជើងឯក ដើម្បីកប់សាកសពអ្នកទោស។ ឈុន ផល បានរៀបរាប់ពីរណ្តៅដែលមានទំហំបីម៉ែត្រ និងជម្រៅពីម៉ែត្រ។ នៅពេលដែលគាត់ឈរក្នុងរណ្តៅនោះ វាមានកំពស់ត្រឹមករបស់គាត់។ ឈុន ផល បានបញ្ជាក់បន្ថែមទៀតថា សាកសពទាំងអស់សុទ្ធតែគ្មានសៀកពាក់អ្វីទាំងអស់ (ស្រាត) ហើយបន្ទាប់ពីរណ្តៅពេញដោយសាកសព ក្រុមរបស់គាត់ដែលមានគ្នាប្រមាណបីទៅបួននាក់ចាប់ផ្តើមកាយដីលុបរណ្តៅ ហើយគាត់បាននិយាយថា "ក្រុមរបស់ខ្ញុំបានចំណាយពេលប្រហែលពីម៉ោងដើម្បីលុបរណ្តៅមួយ។" ឈុន ផល បានប្រាប់ថា គាត់បានកប់សាកសពអ្នកទោសតែមួយប៉ុណ្ណោះ។

បន្ទាប់មកលោកប្រធានចៅក្រម បានអានប្រតិចារឹកនៃបទសម្ភាសន៍ដែលចៅក្រមស៊ើបអង្កេតបានធ្វើជាមួយ ឈុន ផល កាលពីថ្ងៃទី ១៨ មករា ឆ្នាំ២០០៨។ ចម្លើយរបស់ ឈុន ផល ដែលផ្តល់ឲ្យនៅថ្ងៃនេះមិនស៊ីចង្វាក់គ្នាជាមួយនឹងចម្លើយដែលគាត់បានប្រាប់ចៅក្រមស៊ើបអង្កេតឡើយ។ ខណៈពេលដែល ឈុន ផល មិនបានពន្យល់ពីហេតុផលនោះ លោកប្រធានចៅក្រមបានគោរពសិទ្ធិ

សាក្សីក្នុងការមិនឆ្លើយ និងបានសម្រេចមិនចោទសួរបន្តទាក់ទិននឹងបញ្ហានេះ។ ក្រោយមក ឌុច បានចេញយោបល់លើសក្ខីកម្មរបស់ ឈុន ផល ដោយនិយាយថា គាត់ទទួលស្គាល់ថា ឈុន ផល ពិតជាអ្នកយាមមន្ទីរស-២១ម្នាក់មែន។

ក្រោយពីសក្ខីកម្មរបស់ ឈុន ផល បានបញ្ចប់ទៅ អង្គជំនុំជម្រះនឹងកោះហៅសាក្សីបន្ទាប់ទៀត គឺ សំ ម៉ែត អាយុ ៥១ឆ្នាំ មកពីខេត្ត កណ្ដាល។ សំ ម៉ែត បានចូលបដិវត្តន៍នៅឆ្នាំ១៩៧៣ និងបានចូលវាយក្នុងសមរភូមិជាច្រើនលើកដែរ។ មុននឹងក្លាយជាអ្នកយាម គុកដុមដេង ជាគុកមួយដែលបង្កើតឡើងមុនមន្ទីរស-២១បានកកើតឡើង សំ ម៉ែត ត្រូវបានបង្រៀនពីវគ្គហ៊ឹកហ៊ឺនទ័ព និងវគ្គបំពាក់បំប៉ននយោបាយរយៈពេលប្រាំបីខែ។

សំ ម៉ែត បានរៀនត្រឹមតែថ្នាក់ទីមួយ ហើយគាត់មិនចេះអាន និងសរសេរទេ។ រវាងឆ្នាំ១៩៧៧-១៩៧៨ ខ្មែរក្រហមបានបញ្ជូនអ្នកដែលចេះអាន និងសរសេរឲ្យធ្វើជាអ្នកសួរចម្លើយ ចំណែកឯអ្នកមិនចេះអាន និងសរសេរត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកយាម។ ដូចអ្នកយាមដទៃទៀតដែរ សំ ម៉ែត ក៏បានធ្វើស្រែនៅគុក ព្រៃស មុននឹងការដួលរលំនៃរបបខ្មែរក្រហម។

សក្ខីកម្មរបស់ សំ ម៉ែត នឹងបន្តនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩។